វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

INSTITUT DE TECHNOLOGIE DU CAMBODGE

លក្ខន្តិកៈ

STATUTS

បកប្រែទាំងស្រុងពីឯកសារភាសាបារាំងដែលបានចុះហត្ថលេខាដោយលោករដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា អ៊ឹង ហួត
និងលោក Michel GUILLOU អគ្គនាយក/សាកលវិទ្យាធិការ AUPELF/UREF
នៅភ្នំពេញ ថ្ងៃទី ៣ កុម្ភៈ ១៩៩៤

លក្ខន្តិកៈ STATUTS

ជំពូក CHAPITRE ទី I បទបញ្ញត្តិទូទៅ DISPOSITIONS GENERALES

មាត្រា ១_ លក្ខន្តិកៈ STATUT

១_ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាហៅកាត់ថា "អ៊ីតេសេ" (ITC) គឺជាគ្រឹះស្ថានសិក្សាបច្ចេកទេសជាន់ខ្ពស់មួយដែលធានារ៉ាប់រងបេសកកម្មបំរើអភិវឌ្ឍន៍ជាតិនិងភូមិភាគក្នុងនាមជាគ្រឹះស្ថានពហុភាគី (multilatéral) នៅអាស៊ីអាគ្នេយ៍។

២_ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាមានបុគ្គលិកលក្ខណៈគតិយុត្តិ (personnalité juridique) ហើយប្រកបដោយសមត្ថភាព (capacités) ឯកសិទ្ធិ (privilège) និង អភ័យឯកសិទ្ធិ (Immunité) ចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន ដូចដែលបានកំណត់នៅក្នុងពិធីសារនៃការអនុវត្តន៍ (protocole d'application) កិច្ចព្រមព្រៀង (convention) បារាំង_ខ្មែរដែលបានចុះហត្ថលេខានាថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩៣ រវាងរដ្ឋាភិបាលបណ្តោះអាសន្នកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង (ក្រសួងសហប្រតិបត្តិការ) ហើយដែលផ្តល់មុខងារដល់សមាគមសាកលវិទ្យាល័យដែលប្រើភាសាបារាំងទាំងអស់ឬតែមួយភាគ និងសាកលវិទ្យាល័យនៃបណ្តាញភាសាបារាំងអូប៉ែលហ្វ_អ៊ុយរេហ្វ (Association des Universités Partiellement ou Entièrement de Langue Française et Université des Réseaux d'Expression Française AUPELF-UREF) ជាអ្នករ៉ាប់រងផ្តើមដំណើរការ។

មាត្រា ២_ ទីស្នាក់ការ SIEGE

ទីស្នាក់ការរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាស្ថិតនៅភ្នំពេញ។

មាត្រា ៣_ គោលដៅនិងសកម្មភាព OBJECTIFS ET ACTIVITES

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាមានគោលដៅដូចខាងក្រោម :

- បណ្តុះបណ្តាលជាភាសាបារាំងនិងជាភាសាខ្មែរ នូវបណ្តាក្របខ័ណ្ឌមធ្យមចាំបាច់សំរាប់ស្ថាបនាឡើងវិញនិងអភិវឌ្ឍន៍ប្រទេសកម្ពុជា។
- បណ្តុះបណ្តាលជាភាសាបារាំង នូវវិស្វករដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេសអាស៊ីអាគ្នេយ៍និងប៉ាស៊ីហ្វិក ហើយពិសេសប្រទេសកម្ពុជា ដោយធ្វើយ៉ាងណាឱ្យវិស្វករទាំងនោះប្រើភាសាអង់គ្លេសផងដែរ។
- បណ្តុះបណ្តាលជាភាសាបារាំង ក្នុងការស្រាវជ្រាវរបស់អ្នកឯកទេសនៅក្នុងវិស័យវិទ្យាសាស្ត្រសំរាប់វិស្វករ។

មាត្រា ៤_ ការគ្រប់គ្រងគរុកោសល្យ ORGANISATION PEDAGOGIQUE

១_ ការបង្រៀននិងការស្រាវជ្រាវនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ត្រូវរៀបចំគ្រប់គ្រងឡើងនៅក្នុងផ្នែក (départements) នានា ដែលប្រមូលផ្តុំតាមឯកទេសនិមួយៗឬច្រើន។

២_ រយៈពេលសិក្សាមានបីឆ្នាំសំរាប់ សញ្ញាប័ត្រសាកលវិទ្យាល័យបច្ចេកវិទ្យា ដែលត្រូវចេញឱ្យដោយមានចុះមុខឯកទេសដែលពាក់ព័ន្ធ (Diplôme Universitaire de Technologie DUT)។

៣_ សញ្ញាប័ត្រថ្នាក់ វិស្វករនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដែលមានចុះមុខឯកទេសនឹងអាចប្រគល់ដល់និស្សិតដែលបានរៀនចប់ភូមិសិក្សារយៈពេលប្រាំឆ្នាំឬដល់អ្នកជាប់ សញ្ញាប័ត្រសាកលវិទ្យាល័យបច្ចេកវិទ្យា (DUT) ដែលបានរៀនចប់រយៈពេលពីរឆ្នាំថែមទៀត។
នៅក្នុងករណីខាងក្រោយនេះការសិក្សាជាវិស្វករត្រូវបើកឱ្យអ្នកមានសញ្ញាប័ត្រសាកលវិទ្យាល័យបច្ចេកវិទ្យាដែលមានការបញ្ជាក់ថាមានបទពិសោធន៍វិជ្ជាជីវៈចំនួនពីរឆ្នាំយ៉ាងតិច។
ការសិក្សាជាវិស្វករនឹងមានលក្ខណៈភូមិភាគហើយនឹងអាចជ្រើសរើសបណ្តាអណិកជនប្រទេសដទៃដែលបំពេញលក្ខ័ណ្ឌផ្សេងៗដូចបានចែងនៅក្នុងវគ្គមុននេះ (alinéa précédent)។

៤_ លក្ខណៈចូលរៀនការរៀបចំការសិក្សាព្រមទាំងលក្ខណៈទាំងឡាយដែលត្រូវបានទទួលសញ្ញាប័ត្រសាកលវិទ្យាល័យបច្ចេកវិទ្យា ហើយនិង សញ្ញាប័ត្រវិស្វករ ត្រូវបានកំណត់ដោយក្រុមប្រឹក្សាអភិបាលរបស់វិទ្យាស្ថាន។

៥_ តាមសំណើរសុំពីអង្គការវិជ្ជាជីវៈ (organisations professionnelles) ឬកិច្ចការរដ្ឋបាល (services administratifs) សិក្ខាសាលាវិក្រិតអាចរៀបចំបាន។ សិក្ខាសាលាទាំងនេះមានគម្រវត្ថុផ្តល់ដល់ក្របខ័ណ្ឌមធ្យមនិងជាន់ខ្ពស់ ដែលកំពុងបំរើការ នូវការបណ្តុះបណ្តាលបន្ថែមលើឯកទេសណាមួយ។

៦_ ថ្នាក់ភូមិសិក្សាកំរិត ៣ អន្តរជាតិ (3ème cycle) នៃការបណ្តុះបណ្តាលសំរាប់ការស្រាវជ្រាវហើយ និងដោយការស្រាវជ្រាវសំរាប់និស្សិតទាំងឡាយដែលមានសញ្ញាប័ត្រវិស្វករ ឬក៏មានកំរិតសមមូល នឹងត្រូវបង្កើតតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអភិបាលរបស់វិទ្យាស្ថាន។

ជំពូក CHAPITRE ទី II ការគ្រប់គ្រងរដ្ឋបាល ORGANISATION ADMINISTRATIVE

មាត្រា ៥_ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាមាន :

- គណៈកម្មការទ្រទ្រង់ (Comité de soutien) មួយដែលមានសមាសភាពជាអ្នកផ្តល់ជំនួយ (donateurs) និង ឥស្សរជនឧត្តម (personnalités éminentes) ទាំងឡាយ។ ប្រធានក្រុមប្រឹក្សាអភិបាលកើតចេញពីគណៈកម្មការនេះ។
- ក្រុមប្រឹក្សាអភិបាល (Conseil d'administration) មួយដែលមានសមាជិក ១៦ រូប ។
- ក្រុមប្រឹក្សាគរុកោសល្យនិងវិទ្យាសាស្ត្រ (Conseil Pédagogique et Scientifique) ដែលមាននាយកវិទ្យាស្ថានជាប្រធាន។

មាត្រា ៦_ គណៈកម្មាធិការទ្រទ្រង់ LE COMITE DE SOUTIEN

១_ គណៈកម្មាធិការទ្រទ្រង់ធានារ៉ាប់រងឱ្យដំណើរការរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាប្រព្រឹត្តទៅបានសមស្របជាមួយនឹងគោលដៅ ហើយនិងជួយរួមវិភាគទានឱ្យមានការរីកចំរើនដល់វិទ្យាស្ថាន។

២_ គណៈកម្មាធិការនេះមានសមាសភាពអ្នកផ្តល់ជំនួយហើយនិង ឥស្សរជនតំណាងប្រទេសដែលចូលរួមក្នុងដំណើរការ របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ តំណាងទាំងនេះត្រូវបានតែងតាំងដោយក្រុមប្រឹក្សាអចិន្ត្រៃយ៍ភាសាបារាំង (Le Conseil Permanent de la Francophonie) សំរាប់រយៈពេលពីរឆ្នាំដែលបន្តទៀតបាន។

៣_ គណៈកម្មការនេះតែងតាំងប្រធានមួយរូបដែលជាប្រធានក្រុមប្រឹក្សាអភិបាល។ គណៈកម្មការនេះត្រូវប្រជុំតាមការអញ្ជើញនៃប្រធាន។

មាត្រា ៧_ <u>ក្រុមប្រឹក្សាអភិបាល</u> CONSEIL D'ADMINISTRATION

១_ ក្រុមប្រឹក្សាអភិបាលមានសមាសភាពដូចខាងក្រោម ៖

- ៦ រូបតំណាងប្រទេសកម្ពុជា ដែលមាន ៖

  ៣ មកពីមជ្ឈដ្ឋានវិជ្ជាជីវៈ (milieu professionnels) ចាត់តាំងដោយបណ្តារចនាសម្ព័ន្ធតំណាងរបស់គេ

  ៣ ទៀតមកពីក្រសួងនានាចាត់តាំងដោយលោករដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡាដែលមានភារៈឃើវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

- ៨ រូបតំណាងនៃសហគមន៍ប្រើភាសាបារាំងពហុភាគី (francophone multilatérale) ចាត់តាំងដោយអង្គការអូប៉ែល_អ៊ុយរែហ្វ (AUPELF-UREF) ដែលត្រូវរើសតំណាងនេះឱ្យបានសមស្របទៅតាមភូមិសាស្ត្រនៃប្រទេសទាំងឡាយដែលប្រើភាសាបារាំង (bonne présentativité géographique des pays francophones) ។

- ប្រធានគណៈកម្មាការទ្រទ្រង់ដែលជា សមាជិកពេញសិទ្ធិ (membre de droit) របស់ក្រុមប្រឹក្សាអភិបាល ហើយនិងជាប្រធានផង។

- នាយកវិទ្យាស្ថានជាសមាជិកពេញសិទ្ធិរបស់ក្រុមប្រឹក្សាអភិបាល។

- លើកលែងតែសមាជិកពេញសិទ្ធិ សមាជិកក្រុមប្រឹក្សាអភិបាលត្រូវតែងតាំងអណត្តិ ៣ ឆ្នាំដែលអាចបន្តបាន។

២_ ក្រុមប្រឹក្សាអភិបាលត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធានក្នុងមួយឆ្នាំម្តង។ ម្យ៉ាងទៀតក្រុមប្រឹក្សានេះត្រូវប្រជុំពេលណាដែលមានការចាំបាច់ ហើយក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរពីសំណាក់សមាជិកយ៉ាងតិចមានចំនួនពាក់កណ្តាល។ ការស្នើសុំត្រូវប្រាប់កម្មវត្ថុនៃការប្រជុំ។ សមាជិកពុំអាចឱ្យតំណាងមកប្រជុំបានឡើយហើយបើមានអវត្តមានលើសពីបីដងដោយគ្មានការបញ្ជាក់ត្រឹមត្រូវនោះមានន័យថាជាការលាលែងប្រាកដមែន (démission de fait)

៣_ ក្រុមប្រឹក្សាអភិបាលពិនិត្យសំរេច :

- បញ្ហាទាំងអស់ដែលទាក់ទងជីវភាពរបស់គ្រឹះស្ថាន លើការគ្រប់គ្រងគរុកោសល្យនិងរដ្ឋបាល ហើយជាពិសេសក្រុមប្រឹក្សាកំណត់បែបបទនៃការជ្រើសរើស (recrutement) និងការដេញចោល (licenciement) បុគ្គលិកបង្រៀន (personnel enseignant) ។

- លើការបើកឬបិទផ្នែកនានា (ouverture ou fermeture de départements)

- លើសកម្មភាពស្រាវជ្រាវ។
- លើបណ្ណកិច្ចព្រមព្រៀង (convention) ដែលភ្ជាប់វិទ្យាស្ថានទៅនឹងកិច្ចការរដ្ឋបាល សហគ្រាសនិងអង្គការវិជ្ជាជីវៈ។
- លើរបាយការណ៍ពីសកម្មភាពរបស់នាយកវិទ្យាស្ថាន
- លើការយល់ព្រមទទួលអំណោយ (dons) និងបច្ច័យទាន (legs)
- លើការប្រើប្រាស់ប្រាក់ចំណូលទាំងឡាយបានមកពីអំណោយ និង បច្ច័យទាននិង ប្រាក់ជំនួយ។

ក្រុមប្រឹក្សាត្រូវបោះឆ្នោតកំណត់ថវិកា (budget) របស់វិទ្យាស្ថានហើយអនុម័តយល់ព្រម លើគណនេយ្យហិរញ្ញវត្ថុ (comptes financières)។

ក្រុមប្រឹក្សាត្រូវកំណត់សមាសភាពគណៈមេប្រយោគប្រលងចូលនិងការចេញសញ្ញាប័ត្រនានា។

ក្រុមប្រឹក្សាជាអ្នកតែងតាំងនាយករបស់វិទ្យាស្ថាន។

មាត្រា ៨- <u>ក្រុមប្រឹក្សាគរុកោសល្យនិងវិទ្យាសាស្ត្រ</u> LE CONSEIL SCIENTIFIQUE ET PEDAGOGIQUE

ក្រុមប្រឹក្សាវិទ្យាសាស្ត្រនិងគរុកោសល្យ មានសមាសភាពដូចតទៅ ៖

- នាយកសិក្សា Directeur des Etudes
- នាយកស្រាវជ្រាវ Directeur de la Recherche
- អ្នកទទួលខុសត្រូវរបស់ផ្នែកមួយៗ (des Responsables département)
- តំណាងម្នាក់នៃសាស្ត្រាចារ្យដែលបានជាប់ឆ្នោតតាមផ្នែកនិមួយៗ
- និស្សិតពីររូបបោះឆ្នោតតាមផ្នែកនិមួយៗ។

បែបបទនៃការបោះឆ្នោតទាំងអស់ ត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ជាសមាជិកពេញសិទ្ធិរបស់ក្រុមប្រឹក្សានេះនិងជាប្រធានក្រុមប្រឹក្សានេះផង។

ក្រុមប្រឹក្សាត្រូវប្រជុំពីរលើកក្នុងមួយឆ្នាំ តាមការអញ្ជើញពីប្រធានដែលជាអ្នកកំណត់របៀបវារៈ។

ក្រុមប្រឹក្សាពិនិត្យបញ្ហាទាំងអស់ ដែលទាក់ទងទៅនឹងកិច្ចការវិទ្យាសាស្ត្រ (Affaire Scientifiques) គរុកោសល្យហើយនិង ជីវភាពនិស្សិត និងធ្វើរបាយការណ៍ជូនទៅក្រុមប្រឹក្សាអភិបាល។

មាត្រា ៩- <u>នាយកវិទ្យាស្ថាន</u> LE DIRECTEUR

១- នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាអភិបាលសម្រាប់រយៈពេលបីឆ្នាំ។ អាណត្តិនេះអាចបន្តទៀតបាន។ មានតែក្រុមប្រឹក្សាអភិបាលទេដែលអាចព្យួរឬហូតមុខងារពីនាយកបាន។

២- នាយកជាតំណាងវិទ្យាស្ថាន។
នាយកទទួលអំណោយនិងបច្ច័យទានទាំងឡាយដោយមានការយល់ព្រមពីក្រុមប្រឹក្សាអភិបាល។
នាយកបំពេញកិច្ចការឡើងតុលាការស្របតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សា។

៣- នាយកទទួលបន្ទុករដ្ឋបាលផ្ទៃក្នុងនិងសន្តិសុខរបស់វិទ្យាស្ថាន។
នាយកធានាការអនុវត្តន៍សេចក្តីសំរេចរបស់ក្រុមប្រឹក្សាអភិបាល។
នាយកធានាការអនុវត្តន៍សេចក្តីសំរេចរបស់ក្រុមប្រឹក្សាអភិបាល។

នាយកមើលការខុសត្រូវក្នុងការប្រតិបត្តិច្បាប់បទបញ្ជានិងសេចក្តីណែនាំព្រមទាំងដំណើរការរៀបរយនៃការសិក្សា (cours) ការងារប្រតិបត្តិ (travaux pratiques) ហើយនឹងកម្មសិក្សា (stage)។

នាយកជាអ្នកចាត់ចែងកិច្ចការប្រឡងប្រជែង (concours) និងការប្រឡងឡើងថ្នាក់ (examens) ហើយធានារ៉ាប់រងនូវដំណើរការទាំងនោះ។

នាយកចាត់ចែងការជ្រើសរើស បុគ្គលិករដ្ឋបាល បច្ចេកទេស ហើយនឹងបុគ្គលិកបំរើការ (personnel de service) របស់គ្រឹះស្ថាន។

៤_ នាយកគ្រប់គ្រងទ្រព្យសម្បត្តិផ្ទាល់របស់វិទ្យាស្ថាន។ នាយកចុះកិច្ចសន្យាទិញលក់ (marché) នៅតាមច្បាប់អនុញ្ញាតិនិងបទបញ្ជាស្តីពីសំភារះផ្គត់ផ្គង់និងការងារទាំងឡាយ ដែលមានចែងក្នុងឥណទានផ្ទាល់របស់វិទ្យាស្ថាន។ នាយកជាអ្នកចុះហត្ថលេខាលើអនុសញ្ញា (conventions) រវាងវិទ្យាស្ថាននិងអង្គការរដ្ឋបាល សហគ្រាស (entreprise) និងអង្គការខាងវិជ្ជាជីវៈ (organisme professionnel)។ នាយកជាអ្នករៀបចំថវិការហើយ និងគណនេយ្យអភិបាលរបស់វិទ្យាស្ថាន។ នាយកចុះកិច្ចសន្យានិងបញ្ជាការចំណាយសមស្របតាមឥណទានដែលកំណត់យកនៅក្នុងថវិកា។

៥_ រៀងរាល់ឆ្នាំនាយកផ្តល់ឱ្យក្រុមប្រឹក្សាអភិបាលនូវរបាយការណ៍អំពីស្ថានភាពរបស់វិទ្យាស្ថានហើយនិងការកែរលំអទៅអនាគតដែលអាចនឹងមានដល់វិទ្យាស្ថាន។

៦_ នាយកត្រូវមានជំនួយការដោយនាយករងម្នាក់ (Directeur Adjoint) នាយកផ្នែកសិក្សាម្នាក់ (Directeur des Etudes) ទទួលបន្ទុកខាងការរៀបចំចាត់ចែងកិច្ចការគរុកោសល្យ នាយករដ្ឋបាលម្នាក់ (Directeur Administratif) ទទួលបន្ទុកខាងការគ្រប់គ្រង រដ្ឋបាលនិងហិរញ្ញវត្ថុ ហើយនិងនាយកខាងស្រាវជ្រាវម្នាក់ (Directeur de la Recherche)។ នាយកជាអ្នកលើកសំណើរតែងតាំងអស់លោកទាំងនោះសម្រាប់រយៈពេលបីឆ្នាំទៅក្រុមប្រឹក្សាអភិបាល។

មាត្រា ១០_ ផ្នែក DEPARTEMENT

១_ ផ្នែកជាកោសិកាមូលដ្ឋាន (cellule de base) របស់វិទ្យាស្ថាន ក្នុងការសិក្សានិងការស្រាវជ្រាវ។

ផ្នែកមានបុគ្គលិកនិងកិច្ចការទាំងឡាយដែលស្ថិតនៅក្នុងមុខវិជ្ជាដូចគ្នា ឬក៏មុខវិជ្ជាស្រដៀងគ្នា។

២_ ចំនួនផ្នែកនានា ការដាក់ឈ្មោះឱ្យផ្នែកនោះ និងមុខឯកទេសនានាដែលត្រូវបញ្ចូលក្នុងផ្នែកនិមួយៗត្រូវកំណត់ដោយក្រុមប្រឹក្សាអភិបាល។

៣_ នៅក្នុងផ្នែកនិមួយៗមានបង្កើតក្រុមប្រឹក្សាផ្នែក (Conseil de Département) ដែលសម្រេចលើបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងជីវភាពរបស់ផ្នែក។

ក្រុមប្រឹក្សាផ្នែកមានសមាសភាពដូចតទៅ ៖

- បុគ្គលិកសិក្សាក្នុងផ្នែក
- តំណាងបុគ្គលិករដ្ឋបាលនិងបុគ្គលិកបំរើការ (personnel administratif et de service) មួយដែលបានជាប់ឆ្នោតប្រចាំឆ្នាំ។
- តំណាងនិស្សិតដែលបានជាប់ឆ្នោតប្រចាំឆ្នាំ ក្នុងលក្ខ័ណ្ឌកំណត់ដោយក្រុមប្រឹក្សាអភិបាល ហើយ

ដែលមានចំនួនកំរិតត្រឹមមួយភាគបីនៃចំនួនសមាជិកដែលមានក្នុងវគ្គទាំងពីរខាងលើនេះ (dans la limite du tiers des personnes figurant aux deux alinéas précédents)។

៤_ អ្នកទទួលខុសត្រូវទាំងឡាយរបស់ផ្នែក (les Responsables de Département) ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាអភិបាល តាមការស្នើរបស់នាយកវិទ្យាស្ថាន។ អាណត្តិរបស់គេមានបីឆ្នាំហើយអាចបន្តទៀតបាន (trois ans renouvelables) ។

៥_ ក្រុមប្រឹក្សារបស់ផ្នែកត្រូវប្រជុំតាមការអញ្ជើញរបស់អ្នកទទួលខុសត្រូវផ្នែក។ អ្នកទទួលខុសត្រូវផ្នែកត្រូវកោះហៅប្រជុំបើមានសេចក្តីសុំជាលាយលក្ខណ៍អក្សរដោយចំនួនមួយភាគីរបស់សមាជិក។ ពាក្យសុំត្រូវប្រាប់កម្មវត្ថុនៃការប្រជុំ។

<u>ជំពូក</u> CHAPITRE ទី III <u>បែបបទប្រឡងចូល</u> PROCEDURES D'ADMISSION

មាត្រា ១១

១_ ដើម្បីប្រឡងប្រជែងចូលរៀនថ្នាក់អ្នកបច្ចេកទេសជាន់ខ្ពស់ (cycle technicien supérieur) និស្សិតត្រូវមានមធ្យមសិក្សាប័ត្រវិទ្យាសាស្ត្រខ្មែរហើយបានរៀនចប់ថ្នាក់ត្រៀមមួយឆ្នាំ។ ការប្រឡងប្រជែងនេះត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ហើយមាន វិញ្ញាសារបីដែលត្រូវធ្វើខានមិនបាន (trois épreuves obligatoires) គឺគណិតវិទ្យា (mathématiques) រូបវិទ្យា_គីមី (physique-chimie) និង វប្បធម៌ទូទៅ (culture générale)។ ម្យ៉ាងទៀតពិន្ទុលើសពីមធ្យមភាគ (points supérieurs à la moyenne) នៅលើវិញ្ញាសារភាសាបារាំងក៏ត្រូវគិតចូលក្នុងលទ្ធផលដែលបេក្ខជនទទួលបានដែរ។ ការប្រឡងជាប់ចូលរៀននៅវិទ្យាស្ថានត្រូវធ្វើឡើងតាមលំដាប់ពិន្ទុបេក្ខជន (selon le classement des candidats) ។

២_ ការប្រឡងប្រជែងចូលកំរិតសិក្សាវិស្វករ (cycle ingénieur) ត្រូវបានបើកសំរាប់និស្សិតទាំងឡាយណាដែលមានមធ្យមសិក្សាប័ត្រវិទ្យាសាស្ត្រខ្មែរ ម្យ៉ាងទៀតសំរាប់និស្សិតពីប្រទេសនៅអាស៊ីអាគ្នេយ៍និងចាស៊ីហ្វិកដែលបានបញ្ជាក់ត្រឹមត្រូវនូវកំរិតសមមូល ព្រមទាំងបានទទួលស្គាល់ថាមានសម្បទាដោយគណៈមេប្រយោគ។ ការប្រឡងនេះក៏ត្រូវបានរៀបចំឡើងដោយ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា តាមកាលបរិច្ឆេទផ្សេងៗគ្នាហើយដែលបានចុះនៅកថាខ័ណ្ឌ ១ (paragraphe 1) ដើម្បីឱ្យនិស្សិតខ្មែរអាចចូលប្រឡងបានទាំងពីរផងផង។ ការប្រឡងទាំងនេះមានវិញ្ញសាបីត្រូវធ្វើខានមិនបាន (3 épreuves obligatoires) គឺគណិតវិទ្យា រូបវិទ្យា_គីមី ហើយនិង វប្បធម៌ទូទៅ។ ម្យ៉ាងទៀតពិន្ទុដែលលើសពីមធ្យមភាគនៅលើវិញ្ញាសាភាសាបារាំង ដែលជាវិញ្ញាសាមិនតម្រូវ (facultative) ក៏ត្រូវគិតចូលទៅក្នុងលទ្ធផលដែលបេក្ខជនទទួលបានដែរ។ ការប្រឡងជាប់ចូលរៀននៅវិទ្យាស្ថានត្រូវធ្វើឡើងតាមលំដាប់ពិន្ទុរបស់បេក្ខជន។ ការចូលរៀនដោយប្រឡងប្រជែងមួយនៅឆ្នាំទី ៤ ត្រូវទុកសំរាប់អ្នកដែលមានសញ្ញាប័ត្រអ្នកបច្ចេកទេសជាន់ខ្ពស់ (diplôme de technicien supérieur) ដែលមានបទពិសោធន៍វិជ្ជាជីវៈរយៈកាលពីរឆ្នាំយ៉ាង

តិចហើយដែលចេះភាសាបារាំងផង។ នៅក្នុងករណីនេះការប្រឡងប្រជែងចូលរៀននឹង មានវិញ្ញាសាវិទ្យាសាស្ត្រនិងបច្ចេកទេស ហើយនិង វិញ្ញាសាវប្បធម៌ទូទៅ ដែលជាវិញ្ញាសាភាសាបារាំងផង។ វិញ្ញាសាសួរផ្ទាល់មាត់ (épreuve orale) មានលក្ខណៈជាការពិភាក្សាដើម្បីបញ្ជាក់គោលគំនិត (motivation) វប្បធម៌ទូទៅ ហើយនិងការចេះនិយាយភាសាបារាំងរបស់បេក្ខជន។

៣_ ការប្រឡងជាប់ចូលរៀនកំរិតសិក្សាទី៣ (3e cycle) ត្រូវបានបើកតាមមូលដ្ឋានអន្តរជាតិ (sur une base internationale) ចំពោះបេក្ខជនដែលអាចបន្តការបណ្តុះបណ្តាលដោយប្រើភាសាបារាំងបាន។ ការប្រកាសផ្សាយទូលាយមួយនឹងត្រូវធ្វើទៅតាមស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ។ ការជ្រើសនិស្សិតនឹងផ្អែកទៅលើលទ្ធផលនៃការពិនិត្យសំណុំរឿង (une étude du dossier) របស់បេក្ខជន ហើយលទ្ធផលនៃការប្រឡងប្រជែងដោយពិនិត្យសមត្ថភាពបេក្ខជនទាំងខាងវិទ្យាសាស្ត្រនិងបច្ចេកទេស ខាងគោលគំនិត (motivation) ព្រមទាំងលើការចេះភាសាបារាំងផង (connaissance de la langue française)។

មាត្រា ១២_ លក្ខខណ្ឌដើម្បីឡើងថ្នាក់និងលក្ខខណ្ឌទទួល សញ្ញាប័ត្រសាកលវិទ្យាល័យបច្ចេកវិទ្យា និងសញ្ញាប័ត្រវិស្វករនឹងត្រូវកំណត់ដោយក្រុមប្រឹក្សាអភិបាល ក្នុងក្របខ័ណ្ឌនៃភារៈកិច្ចចែងក្នុងមាត្រា ៧ ។

ភ្នំពេញ ថ្ងៃទី ៣ កុម្ភៈ ១៩៩៤

ហត្ថលេខា

Michel GUILLOU អ៊ឹង ហួត

INSTITUT DE TECHNOLOGIE

DU CAMBODGE

STATUTS

STATUTS

CHAPITRE I

DISPOSITIONS GENERALES

ARTICLE I

Statut

1. L'Institut de Technologie du Cambodge ci-après dénommé ITC est un établissement d'enseignement technique supérieur qui assure sa mission au service du développement national et régional en tant qu'établissement multilatéral en Asie du Sud Est.

2. L'Institut de Technologie du Cambodge possède la personnalité juridique et bénéficie de capacités, privilèges et immunités nécessaires à l'exercice de ses fonctions telles qu'elles sont définies par le protocole d'application à la convention franco-cambodgienne signée le 10 septembre 1993 entre le Gouvernement Provisoire du Cambodge et le Gouvernement de la République Française (Ministère de la Coopération) et donnant mandat à l'Association des Universités Partiellement ou Entièrement de langue Française et l'Université des Réseaux d'Expression Française (AUPELF / UREF) pour en assurer la mise en oeuvre.

ARTICLE II

Siège

Le siège de l'Institut de Technologie du Cambodge est à Phnom Penh.

ARTICLE III

Objectifs et activités

L'Institut de Technologie du Cambodge a pour objet :

- de former, en langue française et en langue khmère, des cadres moyens nécessaires à la reconstruction et au développement du Cambodge.

- de former, en langue française, des ingénieurs pour contribuer au développement des pays d'Asie du Sud Est et du Pacifique et en particulier du Cambodge, tout en veillant à ce que ces ingénieurs pratiquent l'anglais.
- de former, en langue française, au niveau de la recherche des spécialistes dans les domaines des sciences pour l'ingénieur.

ARTICLE IV

Organisation pédagogique

1. L'enseignement et la recherche à l'Institut de Technologie du Cambodge sont organisés au sein de départements regroupant une ou plusieurs spécialités.

2. La durée des études est de trois ans pour l'obtention du Diplôme Universitaire de Technologie (DUT) qui est délivré avec mention de la spécialité correspondante.

3. Le diplôme d'ingénieur de l'ITC portant mention de la spécialité pourra être décerné soit à des étudiants ayant suivi un cycle complet de cinq années d'études soit aux diplômés universitaires de technologie ayant suivi deux années d'études complémentaires.

Dans ce dernier cas, la formation d'ingénieurs est ouverte aux diplômés universitaires de technologie jusitifiant d'au moins deux années d'expérience professionnelle.

La formation d'ingénieurs aura un caractère régional et pourra recruter des ressortissants d'autres pays remplissant les conditions prévues à l'alinéa précédent.

4. Les conditions d'admission, l'organisation des études et les conditions d'obtention du diplôme universitaire de technologie et du diplôme d'ingénieur sont fixées par le Conseil d'Administration de l'Institut.

5. Sur la demande d'organisations professionnelles ou de services administratifs, des séminaires de perfectionnement pourront être ouverts. Ils auront pour objet de dispenser aux cadres moyens et supérieurs en situation d'emploi une formation spécialisée complémentaire.

6. Des 3ème cycles internationaux de formation à la recherche et par la recherche ouverts aux étudiants titulaires d'un diplôme d'ingénieur ou d'un titre équivalent seront créés sur décision du Conseil d'Administration de l'Institut.

CHAPITRE II

ORGANISATION ADMINISTRATIVE

ARTICLE V

L'Institut de Technologie du Cambodge comprend :

- un Comité de Soutien composé de donateurs et de personnalités éminentes. Le président du Conseil d'Administration est issu de ce Comité.
- un Conseil d'Administration de seize membres.
- un Conseil Pédagogique et Scientifique présidé par le Directeur de l'Institut.

ARTICLE VI

Le Comité de Soutien

1. Le Comité de Soutien s'assure de la conformité du fonctionnement de l'ITC avec ses objectifs et contribue à son rayonnement..

2. Il est composé des donateurs et de personnalités éminentes représentatives des pays participant au fonctionnement de l'ITC, ces dernières étant désignées par le Conseil Permanent de la Francophonie pour une durée de deux ans renouvelables.

3. Ce Comité désigne en son sein un Président qui est Président du Conseil d'Administration. Il se réunit sur convocation de son Président.

ARTICLE VII

Le Conseil d'Administration

1. Le Conseil d'Administration est constitué de :

- six représentants du Cambodge dont :
  . trois issus des milieux professionnels désignés par leurs structures représentatives ;
  . trois issus des différents services ministériels désignés par le Ministère de l'Education, de la Jeunesse et des Sports, dont relève l'ITC ;
- huit représentants de la francophonie multilatérale désignés par l'AUPELF / UREF qui devra veiller à une bonne représentativité géographique des pays francophones.
- le Président du Comité de Soutien est membre de droit du Conseil d'Administration et en assure la présidence ;
- Le Directeur est membre de droit du Conseil d'Administration.

A l'exception des membres de droit, les membres du Conseil d'Administration sont nommés pour trois ans, ils peuvent être renouvelés dans leur fonction.

2. Le Conseil d'Administration se réunit sur convocation de son Président une fois par an. Il est en outre convoqué toutes les fois que la nécessité l'exige et en tout cas, sur la demande écrite de la moitié au moins de ses membres ; la demande doit énoncer l'objet de la réunion.

La représentation des membres n'est pas autorisée et au-delà de trois absences non justifiées, la démission est de fait.

3. Le Conseil d'Administration délibère :

- sur toutes les questions qui concernent la vie de l'Etablissement sur le double plan de l'organisation pédagogique et administrative et en particulier il définit les modalités de recrutement et de licenciement des personnels enseignants ;
- sur l'ouverture ou la fermeture de départements ;
- sur les activités de recherche ;
- sur les conventions liant l'Institut aux services administratifs, aux entreprises et aux organismes professionnels ;
- sur le rapport d'activité du Directeur ;
- sur l'acceptation des dons et legs en faveur de l'Institut ;
- sur l'emploi des revenus et produits des dons et legs et des subventions.

Il vote le budget de l'Institut et approuve les comptes financiers.

Il arrête la composition des jurys d'admission et de délivrance des diplômes.

Le Conseil nomme le Directeur de l'Institut.

ARTICLE VIII

Le Conseil pédagogique et scientifique

Le Conseil Scientifique et Pédagogique est constitué :

- du Directeur des Etudes ;
- du Directeur de la Recherche ;
- des Responsables de Département ;
- d'un représentant, par département, des enseignants élus ;
- de deux étudiants élus, par départements ;

Les modalités d'élections sont définies par le règlement intérieur de l'ITC.

Le Directeur de l'ITC est membre de droit de ce conseil et le préside.

Il se réunit deux fois par an sur convocation de son président qui fixe l'ordre du jour.

Il examine les questions relatives aux affaires scientifiques, pédagogiques et à la vie des étudiants et fait rapport au Conseil d'Administration.

ARTICLE IX

Le Directeur

1. Le Directeur de l'Institut de Technologie du Cambodge est nommé pour trois ans par le Conseil d'Administration. Son mandat est renouvelable. Le Directeur ne peut être suspendu ou relevé de ses fonctions que par le Conseil d'Administration.

2. Le Directeur représente l'Institut. Il accepte les dons et legs sur avis conforme du Conseil d'Administration. Il exerce les actions en justice conformément aux délibérations dudit Conseil.

3. Le Directeur est chargé de l'administration intérieure et de la police de l'Institut.
Il assure l'exécution des délibérations du Conseil d'Administration.
Il veille à l'observation des lois, règlements et instructions et au déroulement régulier des cours, travaux pratiques et stages. Il règle le service des concours et examens et assure leur déroulement.
Il procède au recrutement des personnels administratifs, techniques et de service de l'établissement.

4. Le Directeur administre les biens propres de l'Institut. Il passe les marchés dans les formes prescrites par les lois et règlements pour les fournitures et les travaux imputables sur les crédits propres de l'Institut. Il signe les conventions liant l'Institut aux services administratifs, aux entreprises et aux organismes professionnels.
Il prépare le budget et les comptes administratifs de l'Institut. Il engage et ordonne les dépenses conformément aux crédits ouverts au budget.

5. Chaque année le Directeur présente au Conseil d'Administration un rapport sur la situation de l'Institut et les améliorations qui peuvent être apportées.

6. Le Directeur est assisté par un Directeur Adjoint, un Directeur des Etudes chargé de l'organisation pédagogique, un Directeur Administratif chargé de la gestion administrative et financière et d'un Directeur de la Recherche. Il propose leur nomination pour trois ans au Conseil d'Administration.

ARTICLE X

Le Département

1. Le Département constitue la cellule de base de l'Institut sur le double plan de l'enseignement et de la recherche. Il regroupe le personnel et les services qui relèvent d'une même discipline ou de disciplines voisines.

2. La liste des départements, leur dénomination et les spécialités qu'ils recouvrent sont fixées par le Conseil d'Administration.

3. Il est institué dans chaque département un Conseil de Département qui délibère sur toutes les questions intéressant la vie du département.

Il est composé :

- des enseignants du département,
- d'un représentant élu chaque année par les personnels administratifs et de service,
- des représentants des étudiants élus chaque année dans des conditions fixées par décisions du Conseil d'Administration dans la limite du tiers des personnes figurant aux deux alinéas précédents.

4. Les Responsables de Département sont nommés par le Conseil d'Administration sur proposition du Directeur. Leur mandat est de trois ans renouvelables.

5. Le Conseil de Département se réunit sur la convocation du Responsable de Département. Celui-ci est tenu de le convoquer sur la demande écrite du tiers de ses membres : la demande doit énoncer l'objet de la réunion.

CHAPITRE III

PROCEDURES D'ADMISSION

ARTICLE XI

1. L'admission au cycle technicien supérieur est réservée à des étudiants titulaires du baccalauréat scientifique cambodgien et ayant suivi une année préparatoire au concours d'admission. Ce concours est organisé par l'Institut de Technologie du Cambodge et comporte trois épreuves obligatoires : mathématiques, physique-chimie et culture générale. D'autre part, les points supérieurs à la moyenne à une épreuve de langue française sont pris en compte dans les résultats obtenus par les candidats L'admission à l'Institut se fait selon le classement des candidats.

2. Le concours d'entrée dans le cycle ingénieur est ouvert d'une part aux étudiants titulaires du baccalauréat scientifique cambodgien et ayant suivi une année préparatoire au concours d'admission, d'autre part aux étudiants des autres pays d'Asie du Sud Est et du Pacifique jusitifiant d'un niveau équivalent et reconnus aptes, par le jury d'admission, à présenter ce concours. Celui-ci est organisé par l'Institut de Technologie du Cambodge à une date différente de celui institué au paragraphe 1 ci-dessus pour permettre aux étudiants cambodgiens de passer les deux concours. Il comporte trois épreuves obligatoires : mathématiques, physique-chimie et culture générale. D'autre part, les points supérieurs à la moyenne à une épreuve de langue française facultative sont pris en compte dans les résultats obtenus par les candidats. L'admission à l'Institut se fait selon le classement des candidats.

Une entrée sur concours en quatrième année est destinée aux titulaires d'un diplôme de technicien supérieur, bénéficiant d'une expérience professionnelle de deux années minimum et ayant une bonne connaissance de la langue française. Dans ce cas, le concours d'entrée s'articulera autour d'un groupe d'épreuves scientifiques et techniques et d'une épreuve de culture générale qui sera en même temps une épreuve de français. Une épreuve orale sous forme de discussion destinée à vérifier les motivations du candidat, sa culture générale et sa connaissance du français oral complètera le dispositif.

3. L'admission en troisième cycle est ouverte, sur une base internationale, à l'ensemble des candidats aptes à suivre une telle formation en langue française. Une large publicité sera diffusée auprès des institutions concernées. La sélection des étudiants résultera d'une étude de dossier et d'un concours destiné à vérifier les capacités des candidats tant sur le plan scientifique et technique, sur le plan de la motivation que sur le plan de la connaissance de la langue française.

ARTICLE XII

Les conditions de passage d'une année à l'année supérieure et les conditions d'obtention des diplômes universitaires de technologie et d'ingénieur seront définies par le Conseil d'Administration dans le cadre de ses attributions définies à l'article VII.

A Phnom Penh le 5 février 1994